# សេចក្តីថ្លែងការណ៍
# ស្តីពី
# បរិយាកាស ក្រោយការបោះឆ្នោតជាតិ នីតិកាលទី៥ ឆ្នាំ២០១៣

រាជធានីភ្នំពេញ, ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៣

ក្រុមអង្គការសង្គមស៊ីវិលមានការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះបញ្ហាបំភិតបំភ័យ ការគំគួន ការគំរាមកំហែងក្នុងចំណោមប្រជាពលរដ្ឋមួយចំនួន និងបញ្ហាហិង្សាដោយពាក្យសម្តីពីក្រុមគាំទ្រគណបក្សនយោបាយមួយ ទៅគណបក្សនយោបាយមួយផ្សេងទៀត ពិសេសការគំរាមកំហែងពីមន្ត្រីថ្នាក់មូលដ្ឋាន ដូចជា មេភូមិ មេឃុំ និងអាជ្ញាធរមួយចំនួនដែលមាននិន្នាការនយោបាយគាំទ្រគណបក្សកំពុងកាន់អំណាច ទៅលើសកម្មជនគណបក្សប្រឆាំង បន្ទាប់ពីការបោះឆ្នោតជាតិ នីតិកាលទី៥ កាលពីថ្ងៃទី២៨ កក្កដា ឆ្នាំ២០១៣ ត្រូវបានបញ្ចប់។

ក្រុមអង្គការសង្គមស៊ីវិលបានសង្កេតឃើញថា ប្រជាពលរដ្ឋនៅតំបន់មួយចំនួនកំពុងទទួលរងនូវការគំរាមកំហែងនិងការវាយប្រហារពាក្យសំដីពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច ដោយសារតែអាជ្ញាធរទាំងនោះបានចោទប្រកាន់ថា មិនបានបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា។ ទង្វើបែបនេះគឺជាសកម្មភាពរំលោភច្បាប់និងរំលោភសិទ្ធិរបស់ពលរដ្ឋដែលស្ថាប័នពាក់ព័ន្ធត្រូវតែចាត់វិធានការជាបន្ទាន់ ក្នុងការទប់ស្កាត់ក៏ដូចជាការដាក់ពិន័យដល់ជនដែលបានប្រព្រឹត្ត។

ក្រុមអង្គការសង្គមស៊ីវិលយល់ឃើញថា ដើម្បីលុបបំបាត់ការសង្ស័យ ការភ័យខ្លាច និងការគំរាមកំហែង និងដើម្បីបង្ហាញឲ្យឃើញនូវការគោរពដល់ឆន្ទៈរបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត និងលើកតំកល់ផលប្រយោជន៍ជាតិជាធំ សូមឲ្យគណបក្សដែលបានជាប់ឆ្នោតទាំងពីរ ចេញប្រកាសសេចក្តីណែនាំជាសាធារណៈទៅដល់អ្នកគាំទ្ររបស់ខ្លួន ក៏ដូចជាអាជ្ញាធរសាធារណៈ កុំឲ្យប្រព្រឹត្តអំពើដែលបង្ករនូវភាពភ័យខ្លាច ភាពរំជើបរំជួលក្នុងសង្គម និងបង្កើតឧបសគ្គផ្សេងៗ ដែលអាចបណ្តាលឲ្យប៉ះពាល់ដល់ការសាមគ្គី និងភាពសុខដុម នៃសង្គមទាំងមូលក្នុងខណៈពេលដែលប្រទេសកម្ពុជាកំពុងរៀបចំរាជរដ្ឋាភិបាលថ្មី។

ក្រុមអង្គការសង្គមស៊ីវិល សូមសំណូមពរដល់ក្រសួងមហាផ្ទៃ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដាក់ចេញនូវវិធានការដើម្បីបញ្ឈប់ជាបន្ទាន់នូវការគំរាមកំហែង តាមគ្រប់រូបភាព ការគំគួន និងការរើសអើងគ្នាទៅវិញទៅមកដោយសានិន្នាការនយោបាយ និងសូមឲ្យអាជ្ញាធរចាត់វិធានការទៅលើជនណាដែលប្រើរូបភាពជាអាជ្ញាធររដ្ឋក្នុងការគំរាមកំហែងប្រជាពលរដ្ឋ។ ក្រុមអង្គការសង្គមស៊ីវិលក៏សូមអំពាវនាវផងដែរដល់ប្រជាពលរដ្ឋទាំងអស់ សូមកុំឲ្យមានការរើសអើងនិន្នាការគណបក្សនយោបាយ កុំឲ្យគំគួនគ្នា ដោយប្រកាន់នូវគុណធម៌ និងការយោគយល់អធ្យាស្រ័យ គ្នាទៅវិញទៅមកក្នុងនាមជាប្រជាពលរដ្ឋខ្មែរ ដែលមានចរិកថ្លៃថ្នូរ ស្រឡាញ់ជាតិ និងសន្តិភាព។

***ព័ត៌មានបន្ថែមសូមទាក់ទង:***


- លោក **សុក សំអឿន** ប្រធានសំរបសំរួល គណៈកម្មាធិការប្រព្រឹត្តិកម្ម (CHRAC) និងជានាយកប្រតិបត្តិ ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) Tel: 012 901 199
- លោក **នីចរិយា** ប្រធានផ្នែកស៊ើបអង្កេតសមាគម អាដហុក (ADHOC) Tel: 011 274 959
- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្រ្វែល (COMFREL) Tel: 012 942 017
- លោក **ហង្សពុទ្ធា** នាយកប្រតិបត្តិ និកហ្វិច (NICFEC) Tel: 012 959 666
- លោក **ម៉ាក់ ចំរើន** ប្រធានសមាគម យុវជនខ្មែរ (KYA) Tel: 017 788 955
- លោក **សួន ប៊ុនស័ក្តិ** លេខាធិការប្រតិបត្តិ CHRAC Tel: 092 344 357